# ស.រ.អា. និង អ.ស.ប.
# ធ្លាក់ចូលក្នុងអន្ទាក់របស់ពួកខ្មែរក្រហម

Les Etats-Unis, l'ONU et les Khmers Rouges

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី៣ ឧសភា ២០០៦

កររណីរបស់លោកយ៉ាស៊ូស៊ុ-អាកាស៊ី ៖

★★★ ដើម្បីជាគតិយុត្តិធម៌ដល់ជនជាតិយួននិងដល់ពួក«ក្បាលយួនខ្លួនខ្មែរ»... ខ្ញុំសូមដកស្រង់សំរាប់ធ្វើការបកស្រាយ នូវអត្ថបទមួយរបស់កាសែតប្រូយួន «ភ្នំពេញថ្មី - CAM-NEWS នៅឡុងប៊ីច លេខ២៨៨- ៨សីហា-១៧សីហា, ២០០១», ដែលមានចំណងជើងថា ៖ «សម្តេចសីហនុបញ្ជាក់ពីមេខ្មែរក្រហមនួន-ជា, ខៀវ-សំផន, អៀង-សារី»... ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

«ព្រះករុណាព្រះមហាក្សត្រកម្ពុជា សម្តេចព្រះនរោត្តម-សីហនុ បានមានបន្ទូលបញ្ជាក់ពីជំហររបស់ព្រះអង្គថា ព្រះអង្គមិនជ្រៀតជ្រែកដល់ការជំនុំជំរះ លើអតីតមេដឹកនាំខ្មែរក្រហមឡើយ ជាពិសេសលើករណីមេឃាតករប្រល័យពូជសាសន៍ និងជាជនកំសាកញីគឺ អៀង-សារី, នួន-ជា និងខៀវ-សំផន ។ ការបញ្ជាក់នេះបានកើតឡើងបន្ទាប់ពីរដ្ឋសភាជាតិបានអនុម័តជាថ្មី លើសេចក្តីព្រាងច្បាប់ ដើម្បីបង្កើតឡើងនូវតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (កកន ៖ ឃើញថានៅចំពោះមុខពួកមេខ្មែរក្រហមកំសាកញី... ព្រះករុណានរោត្តម-សីហនុជាជនកំសាកញីជាងពួកមេខ្មែរក្រហមទៅទៀត ដោយព្រះអង្គមិនហ៊ានជ្រៀតជ្រែកឬរវីរវល់អំពីការជំនុំជំរះលើអតីតមេដឹកនាំខ្មែរក្រហម អំពីបទប្រល័យពូជសាសន៍នោះឡើយ) ។

«នៅក្នុងសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់ព្រះអង្គ ចុះថ្ងៃ១២កក្កដានេះ ព្រះករុណាបានបញ្ជាក់ថា ព្រះអង្គមានកិត្តិយសជំរាបជូនជនរួមជាតិ អំពីតុលាការជំរះ ឬមិនជំរះខ្មែរក្រហម ជាពិសេសជំរះលោកអៀង-សារី, លោកនួន-ជា, លោកខៀវ-សំផនថា ព្រះអង្គមិនជ្រៀតជ្រែកក្នុងរឿងនេះទេ ត្បិតត្រូវជូនរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា និងតុលាការ ដែលត្រូវចាត់តាំងឡើង លោកមានសិទ្ធិនិងករណិយកិច្ចគិតគូរអំពីរឿងនេះ ។ សេចក្តីថ្លែងការណ៍នេះបានបន្តទៀតថា លោកយ៉ាស៊ូស៊ុ-អាកាស៊ី អតីតប្រមុខអ៊ុនតាក់ ដែលបានសួរយោបល់ព្រះអង្គអំពីរឿងនេះ ហើយព្រះអង្គ

គ្រាន់តែជំរាបលោកអាកាស៊ីថា «សំណូមពររបស់ខ្ញុំមានតែបញ្ហាមួយ គឺបញ្ហាថែរក្សាឲ្យបានគង់វង្សជាដរាប សន្តិភាពជូនប្រជារាស្ត្រមានប្រជារាស្ត្រក្រីក្រជាដើម ដែលត្រូវការសន្តិភាព ដើម្បីកសាងជីវភាពរបស់ខ្លួន និងកសាងមាតុប្រទេសកម្ពុ-ជា ឲ្យបានលូតលាស់តទៅមុខទៀត» ។

«គួររំលឹកថា កាលពីថ្ងៃទី១១កក្កដាកន្លងទៅនេះ អតីតប្រមុខអ៊ុនតាក់ គឺលោកយ៉ាស៊ូស៊ុ-អាកាស៊ីបានបង្គំគាល់ព្រះករុណា ហើយបញ្ហាកាត់ទោសខ្មែរក្រហមបានលើកយកទៅនិយាយ ។

«លោកអាកាស៊ីបានផ្តល់ពត៌មានដល់អ្នកកាសែត អំពីជំហររបស់លោក ក៏ដូចជាព្រះមហាក្សត្រដែលថា ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ត្រូវគិតដល់សន្តិភាពនិងស្ថិរភាពសង្គមដែលប្រទេសកម្ពុជាត្រូវការជាចាំបាច់ ។ លោកបានបន្តថា « ព្រះមហាក្សត្របានគូសបញ្ជាក់ថា ខណៈដែលបុព្វហេតុយុត្តិធម៌ត្រូវតែគិតគូរនោះ កិច្ចព្រមព្រៀង និងការចរចាពីមុនជាមួយមេដឹកនាំខ្មែរក្រហម ត្រូវតែយកមកគិតគូរពិចារណា» ។

«ចំណុចនេះបានធ្វើឲ្យមានការបកស្រាយថា ព្រះអង្គមានព្រះទ័យមិនចង់ឲ្យមានការកាត់ទោសលោកអៀង-សារី, នួន-ជា និងខៀវ-សំផន ។

«គួររំលឹកថា លោកអៀង-សារីត្រូវបានព្រះមហាក្សត្រព្រះរាជទានទោសនៅចុងឆ្នាំ១៩៩៦ បន្ទាប់ពីមានសមាជិកសភាចំនួន២ភាគ៣ បានស្នើសុំការលើកលែងទោសនេះ ជាថ្នូរទៅនឹងការផ្តាច់ខ្លួនជាលើកដំបូងរបស់ពួកឧទ្ទាមខ្មែរក្រហមនៅម៉ាឡៃ និងប៉ៃលិន និងតំបន់ផ្សេងៗបន្តទៀត (កកន ៖ សភានោះ គឺជាសភារណប្ញទ្ធិ-ហ៊ុនសែន... ដូច្នេះគឺជាសហការអាមេរិកាំង-យួន ដែលស្រុះស្រួលគ្នាលើកលែងទោសឲ្យពួកមេឃាតករប្រល័យពូជសាសន៍) ។

«នៅក្នុងឆ្នាំ១៩៩៨ មេដឹកនាំខ្មែរក្រហមពីរនាក់ទៀត លោកនួន-ជានិងលោកខៀវ-សំផន បានស៊ីវិលមករស់នៅក្នុងសង្គមជាតិវិញ ហើយនោះគឺជាការដួលរលំទាំងស្រុងនៃក្រុមខ្មែរក្រហម» ។

★★★ យោងតាមអត្ថបទខាងលើនេះ អ្នកផងអាចមើលឃើញយ៉ាងច្បាស់ក្រ-ឡែតថា មានការស៊ីគ្រលុំរវាងយ៉ាស៊ូស៊ី-អាកាស៊ី អតីតមេអ៊ុនតាក់ ជាមួយនិងព្រះមហាក្សត្រខ្មែរ ដើម្បីវាយស្នៀតបញ្ចូលពួកមេខ្មែរក្រហមប្រល័យពូជសាសន៍នួន-ជា, អៀង-សារី និងខៀវ-សំផន ឲ្យមករស់នៅក្នុងសង្គមជាតិវិញ... ប្រហែលគ្នានឹងការបញ្ចូលសត្វខ្លាមកក្នុងក្រោលគោ (ដោយនឹកស្មានថា ខ្លាក្រាប ជាខ្លាសំពះឬអ្វី ??) ។

យើងដឹងថា ព្រះមហាក្សត្រនរោត្តម-សីហនុជាស្តេចជាប់ឃុំគ្រងរបស់យួនរួចទៅហើយ... នៅក្នុងវាំងខ្លួនឯង ទ្រង់ជាប់ឃុំរបស់អ្នកម្នាងម៉ូនិក មេស្រីយៀកកុងបង្កប់ខ្លួនកំពូល... នៅខាងក្រៅវាំង ទ្រង់គ្រាន់តែជាសត្វឆ្កែជាប់ខ្សែប្រឡៅរបស់រដ្ឋ

ការឃួនហេងសរិន-ហ៊ុនសែន, ប៉ុន្តែតើមេអ៊ុនតាក់យ៉ាស៊ូស៊ុ-អាកាស៊ីនោះ វាជាប់ឃុំគ្រងនរណាដែរ បានជាឃុបឃិតយកពួកមេខ្មែរក្រហមប្រល័យពូជសាសន៍ អៀង-សារី, នួន-ជា, ខៀវ-សំផន មកបញ្ចូលក្នុងសង្គមជាតិខ្មែរទៅវិញ នៅពេលដែលដឹងថា «ក្រុមខ្មែរក្រហមកំពុងដួលរលំទាំងស្រុង» នៅព្រំប្រទល់ខ្មែរ-ថៃនោះរួចទៅហើយ... ទាំងនេះគឺជាការប្រោសលោះ ឲ្យពួកខ្មែរក្រហមទាំងមូល មានកម្លាំងនយោបាយនៅក្នុងសង្គមជាតិឡើងវិញទេឬ ? តើយ៉ាស៊ូស៊ុ-អាកាស៊ី អតីតអ្នកតំណាងអ.ស.ប.ដែលបានទទួលបេសកកម្មពិសេស ក្នុងប្រការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា មានគោលជំហរពិតប្រាកដយ៉ាងណាដែរ ?? (គួរជ្រាបថា លោក «អាកាស៊ី-ស៊ីអាកោរវៀតណាម» ក៏មានប្រពន្ធយៀកកុងដូចតែស្តេចសីហនុដែរ)។

★★★ នៅដើមទសវត្ស១៩៩០, ខ្ញុំបានព្រាងលិខិតមួយច្បាប់ បំរុងផ្ញើទៅឲ្យយ៉ាស៊ូស៊ុ-អាកាស៊ី... ប៉ុន្តែខ្ញុំបានយកលិខិតនោះទៅបង្កប់ចោលទៅវិញ ដោយខ្ញុំមានចិត្តខ្លាចក្រែង ថាខ្លួនខ្ញុំមានគតិអយុត្តិធម៌ចំពោះប្រទេសជប៉ុន ដែលខំប្រឹងស្វែងរកសន្តិភាពឲ្យប្រទេសកម្ពុជា ។ ប៉ុន្តែលិខិតព្រាងរបស់ខ្ញុំ ដែលគ្មានតម្លៃសោះកាលពីសម័យនោះ វាប្រែក្លាយទៅជាឯកសារមួយ ដ៏សំខាន់នៅពេលបច្ចុប្បន្ន ដើម្បីវែកមុខមាត់ពិតប្រាកដរបស់យ៉ាស៊ូស៊ុ-អាកាស៊ី ៖

លិខិតចំហជូនចំពោះឯកឧត្តម អាកាស៊ុ...

អភិបាលស៊ីវិលនៃអង្គការសហប្រជាជាតិដើម្បីត្រួតពិនិត្យសន្តិភាពនៅកម្ពុជា

ឡុងប៊ីច, ថ្ងៃទី.......

ឯកឧត្តម,

«ដោយមានសេចក្តីគោរពយ៉ាងជ្រាលជ្រៅចំពោះកិច្ចការរបស់លោកជាបេសកជន, ខ្ញុំសូមសំដែងសេចក្តីសោកស្តាយ, ឯកឧត្តមអាកាស៊ុ, ដោយបានដឹងថា រូបលោកដែលជាតំណាងជាន់ខ្ពស់អ.ស.ប. មានភារកិច្ចកសាងសន្តិភាពនៅប្រទេសកម្ពុជា និងជាអ្នកទទួលរៀបចំការបោះឆ្នោតនីតិបញ្ញត្តិនៅក្នុងឆ្នាំ១៩៩៣... លោកបែរជាប្រើអំណាចរំលោភលើសិទ្ធិជនជាតិខ្មែរទៅវិញ ដោយធ្វើបុកខ្លួនឯងជាអ្នកចេះដឹង បង្ហាត់បង្រៀនខ្មែរឲ្យនិយាយភាសាខ្មែរ ។

«នៅក្នុងពេលថ្មីៗនេះ លោកបានបង្គាប់បញ្ជាឲ្យជនជាតិខ្មែរទាំងអស់នៅប្រទេសកម្ពុជា (ដោយរាប់បញ្ចូលទាំងឯកឧត្តមសឺន-សាន និងខៀវ-សំផនផងដែរ) ឲ្យឈប់ប្រើពាក្យ«យួន», ពោលគឺត្រូវជំនួសដោយពាក្យ«វៀតណាម»វិញ, បើពុំនោះសោតទេ ពួកអ្នកទាំងនេះនឹងត្រូវជាប់ទោសពិរុទ្ធចូលក្នុងពន្ធនាគារទាំងអស់គ្នា ។ ខ្ញុំមានចម្ងល់ខ្លាំងណាស់ តើឯកឧត្តមបានទទួលយកអំណាចវប្បធម៌នេះពីខាងណាមក... ពីព្រោះថាចំពោះរូបខ្ញុំផ្ទាល់ វាគ្មានអំណាចណាមួយនៅលើភពផែនដីនេះ ក្រៅពីអំណាចរបស់កម្ពុជា ដែលអាចផ្តល់មេរៀនដល់រូបខ្ញុំ ក្នុងប្រការសិក្សាភាសាខ្មែរនោះទេ ។ គឺវាហាក់ដូចជាថា រូបខ្ញុំជាជនជាតិខ្មែរ បែរជាមានសិទ្ធិផ្តល់មេរៀ

នជាភាសាជប៉ុន ទៅដល់ឯកឧត្តមអាកាស៊ីទៅវិញដូច្នោះដែរ ។

«ពាក្យថា«យួន», បើយោងតាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំផ្ទាល់, គឺមានដើមកំណើត៧៥០ឆ្នាំមកហើយ... តាំងពីគ.ស.១២៦០មកម្ល៉េះ គឺជាឈ្មោះរបស់រាជការម៉ុងគោ្គល ដែលត្រួតត្រាប្រទេសចិន នៅក្នុងជំនាន់ស្ដេចអធិរាជគូប៊ីឡៃ-ខាន់, ដែលត្រូវជាចៅរបស់ស្ដេចយ៉េនឃីស-ខាន់ ។ សូម្បីតែសព្វថ្ងៃនេះ ក៏ប្រាក់ចិនមានឈ្មោះថាមួយ«យួន» ឬពីរ«យួន»ដែរ... ពោល«យួន»មានន័យថាស្ដេចចិន (ដូចពាក្យ«រៀល» មានន័យថាស្ដេចខ្មែរ – Riel មកពីពាក្យ Royal) ។ ចំណែកពាក្យថា «វៀតណាម»វិញ ទើបនឹងចាប់ផ្ដើមជីវិតនយោបាយរបស់ខ្លួន នៅក្នុងទសវត្ស៦០តែប៉ុណ្ណោះ... ជាពិសេសនៅក្នុងរយៈពេលនៃសង្គ្រាមអាមេរិកាំង-វៀតណាម ។ ខ្ញុំបានស្វះស្វែងធ្វើការសិក្សាស្រាវជ្រាវត្រង់ចំណុចនេះ ក៏ព្រោះតែមានសំណើរបស់លោកគ្រូគង្វាលអាមេរិកាំងម្នាក់ (Le révérend Paul Ellison) នៅកាលីហ្វ័រនីញ៉ា ដែលជាអ្នកសិក្សាស្រាវជ្រាវផ្នែកវប្បធម៌ខ្មែរម្នាក់យ៉ាងជ្រៅជ្រះ ហើយដែលបានសួរខ្ញុំកាលពីរយៈពេល១០ឆ្នាំមុន ថា«ហេតុម្ដេចបានជាជនជាតិលាវ ហៅប្រជាជនវៀត-ណាម ថាជា«យួន»ដូចខ្មែរផងដែរ ?» ។

«នៅសម័យប្រូតិចតូរ៉ាបារាំងទៅលើប្រទេសកម្ពុជា, ពួកបារាំងមានទម្លាប់ហៅយួនថា ជាពួកអណ្ណាម (les Annamites) ។ ពួកខ្មែរក៏ធ្វើតាមចៅហ្វាយនាយដោយហៅពួកយួនក្នុងភាសាបារាំងថា ជា«ពួកអណ្ណាម»ដូចគ្នាដែរ ។ ប៉ុន្តែនៅក្នុងភាសាខ្មែរវិញ ពួកខ្មែរនៅហៅយួនថាយួន ។ ដូច្នេះក្បែរមួយសតវត្ស ពួកអាណានិគមបារាំង អតីតចៅហ្វាយនាយរបស់យើង មិនដែលឃើញហាមឃាត់ខ្មែរយើងដល់ម្ដងណាសោះ ថាមិនឲ្យប្រើពាក្យ«យួន»នេះ ។ ចុះហេតុម្ដេចបានជាឯកឧត្ដមអាកាស៊ីដែលមិនមែនជាចៅហ្វាយនាយរបស់យើងផងសោះ ហើយដែលគេបានចាត់ទុកថាជាអាជ្ញាកណ្ដាល សំរាប់ដោះស្រាយបញ្ចប់រឿងបញ្ហាជម្លោះវិវាទរវាងខ្មែរយើង និងពួកវៀតណាមឈ្លានពាន (ឬពួកចោរយួនប្លន់ទឹកដី), ហេតុអ្វីបានគ្រាន់តែចូលកាន់មុខតំណែងភ្លាម លោកមានអាការៈប្រហើនកោងកាច មានចិត្តក្រអឺតក្រទមក្នុងករណីប្រើលទ្ធិអំណាចផ្ដាច់ការ ក្នុងនាមជាបញ្ញាជនក្លែងក្លាយ បង្កើតភេរវកម្មខាងផ្នែកវប្បធម៌ (le terrorisme culturel) ដែលសូម្បីតែពួកបារាំង ក៏មិនដែលហ៊ានប្រព្រឹត្តទាល់តែសោះ ។

«ឯកឧត្តមអាកាស៊ី, ភាសាខ្មែរក៏មានលក្ខណៈពិសេស ដូចតែភាសាដទៃទៀតដែរ ។ នៅក្នុងខ្មែរពាក្យថា«វៀតណាម»ក៏ដូចពាក្យថា«កម្ពុជា»... គឺសំដៅទៅលើទិដ្ឋភាពទូទៅ (abstrait) ទៅលើលក្ខណៈរួមនៃសង្គមជាតិ ៖ ឧទាហរណ៍កងទ័ពវៀតណាម ។ ចំណែកពាក្យថា«យួន» ក៏ដូចពាក្យថា«ខ្មែរ» គឺច្រើនតែសំដៅទៅលើទិដ្ឋភាពប្លែកៗ, លក្ខណៈពិសេសរបស់បុគ្គល (concret) ៖ ឧទាហរណ៍ស្រីយួន, យកប្រពន្ធយួន, សម្លម្ជូរយួន ។ ដូចជាពាក្យថា «យកប្រពន្ធយួន» តើមានលក្ខណៈ

ប្រកាន់ពូជសាសន៍ត្រង់កន្លែងណាទៅ ? បើជនជាតិខ្មែរជាអ្នកប្រកាន់ពូជសាសន៍... ហេតុអ្វីបានជាទៅ«យកប្រពន្ធយួន ?» ?

«ឯកឧត្តម, ជនជាតិខ្មែរគឺជាអ្នករងគ្រោះរបស់ពួកយួនឈ្លានពាន, ប៉ុន្តែលោកចាត់ទុកពួកយើងជាពួកចោរប្លន់ទឹកដីទៅវិញ ដោយបង្ខំឲ្យយើងនិយាយភាសាមួយដែលមិនមែនជាភាសារបស់យើង ។ លោកចាត់ទុកពួកខ្មែរយើង ជាពួកជនប្រកាន់ពូជសាសន៍ នៅក្នុងកាលៈទេសៈមួយ ដែលប្រជាពលរដ្ឋខ្មែរកំពុងធ្លាក់ទន់ខ្សោយ និងត្រូវទទួលរងគ្រោះរលត់រលាយរូបបាត់បង់ពីផែនទីពិភពលោកនេះ !! ចំណែកពួកយួនដែលបានបំផ្លិចបំផ្លាញប្រទេសយើង រហូតដល់ក្លាយជាផេះ បែរជាមានសិទ្ធិគ្រប់យ៉ាងទៅវិញ ។ ពួកវាកំពុងតែប្រមាថមាក់ងាយពួកជនជាតិខ្មែរ ដែលរស់បរទេសយ៉ាងជាក់ស្ដែងអស្ចារ្យ... ដោយទុកពួកយើងជា«អណិកជន» ពោលជាប្រជាជនភាគតិច គឺបានសេចក្តីថា ប្រទេសកម្ពុជាបច្ចុប្បន្នបានទទួលវៀតណាមូបនិយកម្មខ្ទេចខ្ទីអស់ទៅហើយ ។

«ឯកឧត្តមអាកាស៊ី, ខ្ញុំមានកិត្តិយសសង្កេតឃើញថា លោកគ្រាន់តែជាសត្វសេកមួយតែប៉ុណ្ណោះ, គ្រាន់តែជាអាយ៉ងមួយរូប ដែលលក់ខ្លួនបំរើប្រយោជន៍របស់ជនជាតិយួន ។ តើប្រទេសកម្ពុជាដែលត្រូវបាត់បង់លក្ខណៈជាតិខ្មែរ ដោយសារតែទង្វើរបស់វៀតណាម... និងប្រទេសកម្ពុជា ដែលទទួលវៀតណាមូបនិយកម្មគ្មានសល់ចន្លោះត្រង់ណាដោយសារប្រទេសជប៉ុន ដែលមានរូបលោកជាអ្នកតំណាងដ៏ឧត្តុងឧត្តម... តើវាខុសប្លែកគ្នាត្រង់ណាទៅ ? ។ ឯកឧត្តម, លោកច្បាស់ជាអាចផ្តល់ផលប្រយោជន៍យួនយ៉ាងធំដល់ប្រទេសកម្ពុជា ប្រសិនបើជាលោកអាចដកថយជាប្រញាប់ពីមុខតំណែងបច្ចុប្បន្ន ដើម្បីទៅសំរាកនៅទីកន្លែងសមគួរ សំរាប់រូបលោកតែម្តង ៖ គឺធុងសំរាមនៃប្រវត្តិសាស្ត្រ ។

ដោយសេចក្តីអំណរគុណទុកជាមុន និងកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅ...» ។

★★★ នៅទីបំផុតយើងអាចដឹងថា ទ្រឹស្តីដែលចែងថា ជនខ្មែរជាមនុស្សប្រកាន់ពូជសាសន៍ ដោយហៅយួនថាយួននេះ... គឺជាគំរោងប្លន់ទឹកដីរបស់ក្រុងហាណូយទៅវិញសោះ ។ នៅក្នុងប្រការនេះ គេអាចមើលឃើញនូវការឃុបឃិតនៃប្រទេសជប៉ុន, អង្គការសហប្រជាជាតិ និងស.រ.អា. ជាមួយនឹងគំរោងប្រល័យពូជសាសន៍ខ្មែរ ដែលរៀបចំឡើងដោយហូ-ជីមិញ ។ ដូច្នេះនៅក្នុងសម័យអ៊ុនតាក់... តើប្រជាជនខ្មែរស្លូតត្រង់ប៉ុន្មាននាក់ទៅ ដែលត្រូវគេអូសកយកទៅដាក់គុកច្រវាក់ ឬយកទៅពិឃាត ដោយគ្រាន់តែប្រើពាក្យថា ៖ «សម្លម្ជូរយួន» ប៉ុណ្ណោះ ?? ដូច្នេះគ្រាន់តែខ្មែរហៅយួនតាមតែឈ្មោះនាមរបស់វានោះសោះ ក៏ត្រូវមានទោសដល់ទៅស្លាប់ផងដែរ !! ចំណែកនយោបាយគៀងគរ យកពួកមេខ្មែរក្រហមប្រល័យពូជសាសន៍ចូលទីក្រុងភ្នំពេញវិញ ហើយដែលមានសហការពីប្រទេសខាងលិច និងអង្គការសហប្រជាជាតិ... នោះក៏ជាគោលបំណងដ៏សម្ងាត់របស់យួនឈ្លានពានផងដែរ ពី-

ព្រោះជាមធ្យោបាយយកខ្មែរខាងក្រៅមកសម្លាប់ខ្មែរខាងក្នុង... ឬក៏យកខ្មែរនៅខាងក្នុង ទៅសម្លាប់ខ្មែរនៅខាងក្រៅ ។ គេនៅចាំបានថា ពេលដែលលោកខៀវ-សំផននិងនួន-ជា មកចុះចូលរដ្ឋាភិបាលនៅក្នុងឆ្នាំ១៩៩៨ ក៏មានវត្តមានរបស់លោកប៊ូត្រូស-ប៊ូត្រូស ក្កាលី អតីតអគ្គលេខាធិការនៃអ.ស.ប. (មុនលោកកូហ្វី-អាណាន់) ទៅទទួលស្វាគមន៍យ៉ាងកក់ក្ដៅ ចំពោះការត្រឡប់វិលវិញ របស់លោកខៀវ-សំផន ចូលក្នុងសង្គមជាតិផងដែរ ។ ប៉ុន្តែវាមិនមែនជាបរាជ័យរបស់ពួកខ្មែរក្រហម វាបែរទៅជាបរាជ័យយ៉ាងជូរចត់, យ៉ាងជាក់ស្ដែង, យ៉ាងទាន់ហន្តរបស់ពួកឈ្លានពានទៅវិញសោះ ។ ពីព្រោះពេលនោះ នៅចំពោះក្រសែភ្នែកនៃពិភពលោកតែម្ដង ហ៊ុន-សែនមិនបានចាប់ពួកអតីតនាយថៅហ្វាយរបស់ខ្លួន យកទៅដាក់គុកគាត់បែរជាទទួលអៀង-សារី, នួន-ជា និងខៀវ-សំផន ក្នុងឋានៈជាគ្រូឧបជ្ឈាយ៍ និងជាមេដឹកនាំកំពូលនៃពួកខ្មែរក្រហមនៅផ្ទះរបស់ហ៊ុន-សែន កាលពីឆ្នាំ១៩៩៨នេះគឺពួកគេចង់សំដែងឲ្យឃើញថា ៖

ទី១- ពួកមេដឹកនាំខ្មែរក្រហមទាំងអស់ តាំងពីប៉ុល-ពតមកដល់ហ៊ុន-សែន ដោយឆ្លងកាត់តាមរយៈតាម៉ុក ពុំមានការបែកបាក់គ្នាទេ... ហើយក៏កំពុងធ្វើដំណើរជាមួយគ្នាទៅរកជោគជ័យដ៏«មហារុងរឿង» និងដ៏ «មហាលោតផ្លោះ» ។

ទី២- ហ៊ុន-សែនមិនមែនជាមនុស្សរបស់យួនទេ តែជាមនុស្សរបស់ចិន ។

ទី៣- ប្រការដែលហ៊ុន-សែនបានដឹកនាំបាតុកម្ម វាយខៀវ-សំផនបែកក្បាលកាលពីឆ្នាំ១៩៩២, ប្រការដែលតាម៉ុកពិឃាតគ្រួសារលោកសុន-សេន ដោយយកត្រាក់ទ័រកិន ដូចគេហាលត្រីងៀតក្នុងឆ្នាំ១៩៩៧ និងការចាប់ប៉ុល-ពតមកដាក់ទោស និងសម្លាប់នៅដើមឆ្នាំ១៩៩៨... គឺជាការសំដែងល្ខោនកំប្លុកកំប្លែងនៅចំពោះភ្នែកពិភពលោកដ៏ភ្លឹកភ្លាំងថា ពួកក្រុមខ្មែរក្រហមកំពុងដួលរលំទាំងស្រុងហើយ ដើម្បីបញ្ឆោតឲ្យអាមេរិកាំងដេញចាប់ ។ ពីព្រោះពួកខ្មែរក្រហមមានបំណងចង្អុលបង្ហាញថា ពួកអ្នកដេញចាប់ខ្មែរក្រហមយកមកកាត់ទោសនោះហើយ ជាពួកឃុបឃិតជាមួយនឹងពួកឈ្លានពាន ដើម្បីប្រល័យពូជសាសន៍កម្ពុជា ។

ទី៤- សព្វថ្ងៃពួកខួរក្បាលធំៗ សំរាប់ដេញតាមចាប់ពួកខ្មែរក្រហម ត្រូវបានរលត់រលាយខ្លួនអស់ទៅហើយ ។ Nates Thayer ក្លាយទៅជាមនុស្សឆ្កួតលីលា ។ Ben Kiernan និង Steve Heder ត្រូវបាត់ឈ្មោះបោះសម្លេង រលត់ទាំងស្រមោលថែមទៀត ។ នៅពេលដែលមេខ្មែរក្រហមម្នាក់ៗ មានមាឌដូចយក្សទៅហើយ ពួកខាងអាមេរិកាំងមានតែមនុស្សតឿ ដែលគេប្រើឲ្យសុំភ្លើងយក្ស ៖ អ្នកស្រីជា-វណ្ណាត ដែលកំពុងយល់សប្តិចង់បានរង្វាន់ណូបែលនៃសន្តិភាព, អ្នកស្រីពុង-ឈីវក្កិក (ហៅ ក្កិក-កាឡាប្រូ), លោកដុកទ័រ (ម្រេញគង្វាល) ឡៅ-ម៉ុងហៃ...។ នៅទីបំផុតគឺនៅសល់កូនសត្វគ្រលីងគ្រលោងមួយដែរ គឺលោក ឆាង-យុ សំរាប់ដេញតាមចាប់សត្វឥន្ទ្រីយ៍ឈ្មោះអៀង-សារី... ព្រោះអៀង-សារីគាត់ទៅណាមកណា ជិះសុទ្ធ

តែឧទ្ធម្ភាគចក្រ ។

❑

## ព្រឹត្តិការណ៍ដ៏សំខាន់ជាងគេនៅក្នុងឆ្នាំ១៩៩៧

នៅក្នុងឆ្នាំ១៩៩៧, ប្រទេសចិនកំពុងតែលេចធ្លោឡើង ជាមហាអំណាចសេដ្ឋកិច្ចដ៏សន្ធោរសន្ធៅ ដែលកំពុងគ្របសង្កត់ទៅលើប្រទេសជប៉ុន នៅពេលដែលប្រទេសជាច្រើននៅអាស៊ី ពឹងពាក់យ៉ាងខ្លាំងទៅលើប្រាក់យ៉េន មានថៃ កូរ៉េខាងត្បូង និងឥណ្ឌូណេស៊ី កំពុងរមៀលធ្លាក់ទៅក្នុងវិបត្តិសេដ្ឋកិច្ច ស្ទើរតែដល់ថ្នាក់ធនក្ស័យ ។ ការងើបឡើងរបស់ប្រទេសចិនបែបដូចនេះ ជាការភ័យខ្លាចនៃក្រុមប្រទេសខាងលិចជាយូរយារណាស់មកហើយ ពីព្រោះរដ្ឋមន្ត្រីបារាំងម្នាក់ឈ្មោះ Alain Peyrefitte បានបោះពុម្ពផ្សាយវណ្ណកម្មមួយដ៏ល្បីល្បាញ ដែលមានឈ្មោះថា «កាលណាប្រទេសចិនងើបឡើង ពិភពលោកទាំងមូលនឹងត្រូវភ័យញាប់ញ័រ» («Quand la Chine s'éveillera, le monde tremblera») ។ ការងើបឡើងទទួលឋានៈជាមហាអំណាចទី១អាស៊ីនៃប្រទេសចិន នៅក្នុងឆ្នាំ១៩៩៧... គឺបានសេចក្តីថា នៅក្នុងឆ្នាំដដែលនេះ ក្រុមប្រទេសទាំងប៉ុន្មាន ដែលបានព្រួតគ្នាតាំងពីបូរាណកាលមក ដើម្បីឡោមព័ទ្ធប្រទេសចិន ក្នុងគោលប្រាថ្នាឲ្យមានការរាំងស្ទះខាងផ្នែកសេដ្ឋកិច្ច កំពុងទទួលបរាជ័យដ៏ល្វីងជូរចត់ (មានស.រ.អា, អឺរ៉ុប, រុស្ស៊ី, អូស្ត្រាលី, ជប៉ុន, ឥណ្ឌូណេស៊ី, ឥណ្ឌា និងវៀតណាម) ។ ក្នុងប្រការនេះ ប្រទេសដែលបានចងសម្ព័ន្ធមេត្រីជាមួយចិន (ទាំងខាងយោធានិងទាំងខាងសេដ្ឋកិច្ច) មានតែកម្ពុជាប្រជាធិបតេយ្យមួយគត់នៅលើភពផែនដីនេះ ។ ដូច្នេះសេចក្តីសង្ឃឹមរបស់វៀតណាម ថាលេបប្រទេសកម្ពុជាបាននោះ គឺត្រូវស្លាប់នៅពេលនេះឯង ។ ម្ល៉ោះហើយ ការប្រឹងប្រែងទាំងប៉ុន្មានរបស់វៀតណាម ដើម្បីយកជ័យជំនះទៅលើពួកខ្មែរក្រហម ក៏បានប្រែក្លាយទៅជាមោឃ: ។ មិនត្រឹមតែប៉ុណ្ណោះសោត... ឥណ្ឌូចិនរបស់យួនកំពុងតែប្រែក្លាយបន្តិចម្តងៗ ទៅជាឥណ្ឌូចិនរបស់ខ្មែរ, ទៅជាមហារដ្ឋកម្ពុជា ដូចជាសម័យបូរាណកាល (ឥណ្ឌា -- គឺជាខ្មែរអង្គរវត្ត... មានព្រះព្រហ្ម, ព្រះឥសូរ និងព្រះនរាយ ចំណែកចិន គឺរូបយើងទាំងអស់គ្នានេះឯង... យើងគួរតែឆ្លុះកញ្ចក់មើល... តើមានខ្មែរណាដែលមិនមែនកូនចៅចិន, សូម្បីអ៊ី-ឈាន ចៅហ្វាយក្រុងចាមនៅប៉ៃលិន ក៏មានឈ្មោះជាចិនដែរ) ។ បូករួមសេចក្តីទៅ ការងើបឡើងនៃប្រទេសចិន គឺជាការត្រូវឆ្នោត Jackpot របស់ពួកខ្មែរក្រហម ព្រមទាំងជាការរលត់រលាយខ្លួនរបស់វៀតណាម ។ «ចៅហ្វាយឡើងបុណ្យ ខុនឡើងស័ក្តិ (ចិន, ខ្មែរក្រហម) ចៅហ្វាយជាប់ច្រវាក់ ខុនដាក់មេប្រុយ (សូវៀត, វៀតណាម)» ។ (ខ្ញុំសូមបើវង់ក្រចកត្រង់ចំណុចនេះដើម្បីបង្ហាញថា នៅក្នុងពេលបច្ចុប្បន្ន មានការផ្គូផ្គងភ្ជាប់មេត្រី រវាងតំបន់ហៃ-ណាន់និងកំពង់ចាម, យូណាន់និងសៀមរាប, ក្រុងសៀងហៃនិងទីក្រុងភ្នំពេញ,

ក្វាងជីប្រហែលជាមួយបាត់ដំបង ។ នៅក្នុងពេលថ្មីៗនេះ លោកចៅ-ហ្វ៊ីជុន លេខាធិការបក្សកុម្មុយនិស្តនៅទីក្រុងក្វាងជី បានធ្វើដំណើរមកកម្ពុជា ដើម្បីធ្វើអំណោយជាគោយន្ត១០០គ្រឿង, ត្រាក់ទ័រ១០០គ្រឿង, ម៉ាស៊ីនបូមទឹក២០០គ្រឿង... គឺជាការចាប់ផ្តើមបង្កើនភោគផលកសិកម្មរបស់ខ្មែរ ដោយប្រើកម្លាំងម៉ាស៊ីន ។ ប៉ុន្តែទាំងនេះគ្រាន់តែជាអំណោយនិមិត្តរូបប៉ុណ្ណោះ... អំណោយពិតប្រាកដ គឺការធ្វើប្រទេសចិនឲ្យទៅជាផ្សារសំរាប់បង្ហូរភោគផលរបស់ខ្មែរ ព្រមទាំងធ្វើប្រទេសខ្មែរឲ្យទៅជាផ្សារសំរាប់ភោគផលរបស់ចិន... ដូច្នេះនៅគ្រប់ប្រទេសនៅក្នុងលោក ត្រូវតែនាំគ្នារត់ត្របាញ់ ទៅដាក់វិនិយោគទុននៅកម្ពុជា) ។

★★★ យើងសូមវិលត្រឡប់មកឆ្នាំ១៩៩៧ឡើងវិញ ។ គឺឆ្នាំនោះហើយដែលប្រទេសចិន, បន្ទាប់ពីបានបាត់បង់ឯករាជ្យទឹកដីអស់១៥០ឆ្នាំ, បានទទួលកោះហុងកុងពីចក្រភពអង់គ្លេសមកវិញ ។ ហើយនៅក្នុងឱកាសសម្ពោធនៃឯករាជ្យពេញលេញម្ចាស់ការនៃប្រទេសចិននេះហើយ ដែលមានផ្ទុះសង្គ្រាមជាសម្ងាត់ ប៉ុន្តែជាសង្គ្រាមស្លាប់រស់ រវាងអាមេរិកាំងនិងចិន ដើម្បីដណ្តើមឥទ្ធិពលនៅកម្ពុជា... តាមរយៈការវិវាទដោយចំហររវាងរណឫទ្ធិហើយនិងហ៊ុន-សែន ។ គេនៅចាំបានថា នៅពេលដែលអ្នកស្រី Madeleine Albright រដ្ឋមន្ត្រីការបរទេសអាមេរិកាំង ធ្វើដំណើរទៅហុងកុង ក្នុងនាមជាភ្ញៀវកិត្តិយសរបស់ចិន ដើម្បីសម្ពោធការត្រឡប់វិលវិញនៃកោះនេះ អ្នកស្រីបានចុះទៅទីក្រុងភ្នំពេញ ដើម្បីឲ្យទឹកពួកស្តេច ក្នុងប្រការឲ្យសម្លាប់ពួកហ៊ុនសែន ។ ពត៌មានក្រៅផ្លូវការបានឲ្យដឹងថា ដើម្បីជាជោគជ័យដល់រដ្ឋប្រហារនេះ, លោកប្រធានាធិបតីគ្លិនតុន បានផ្តល់ជំនួយលើកទឹកចិត្តជាសម្ងាត់ដល់ពួកស្តេច តាមរយៈសិង្ហបូរី នូវទឹកប្រាក់៦លានដុល្លារ ។ កាលនោះពួកស្តេចមានសេចក្តីសង្ឃឹមថា ពួកគេនឹងបានទទួលជ័យជំនះទាំងស្រុង ដោយព្រោះពួកគេមានសហរដ្ឋអាមេរិកនៅពីក្រោយខ្នង, ម្យ៉ាងវិញទៀតពួកគេអាងទៅលើ«ពួកក្បាលឃ្មួនខ្លួនខ្មែរ» ដែលនៅជុំវិញហ៊ុន-សែន មានហេង-សំរិន, ជា-ស៊ីម, ស-ខេង, ហុក-ឡុងឌី ដែលបានចុះចូលជាមួយស្តេចសីហនុរួចអស់ទៅហើយ ហើយដែលយល់ព្រមសហការជាមួយអាមេរិកាំង ដើម្បីសម្លាប់បំផុតពូជពួកខ្មែរក្រហម ។ នៅពេលនោះ សហរដ្ឋអាមេរិកមានគោលបំណងបំបាក់មុខប្រទេសចិន ដែលកំពុងទទួលឯករាជ្យពេញលេញ ដោយបង្កើតឲ្យមានកល្លិយុគធ្ងន់ធ្ងរនៅកម្ពុជា ក្នុងប្រការឲ្យកងទ័ពវៀតណាមវិលត្រឡប់ចូលក្នុងទឹកដីខ្មែរវិញ ៖ ពោលដោយបញ្ឆោតឲ្យមេខ្មែរក្រហមខៀវ-សំផន ដេញតាមសម្លាប់មេខ្មែរក្រហមហ៊ុន-សែន ព្រមទាំងជំរុញឲ្យកម្ពុជាធ្លាក់ចូ-លក្នុង«ឆ្នាំសូន្យ»សាជាថ្មី ។ ដូចអ្នកផងដឹងស្រាប់រួចមកហើយ ទង្វើរបស់អាមេរិកាំងនេះ បានទទួលបរាជ័យដ៏មហាខ្លោចផ្សារ ដោយពួកអាមេរិកាំងនិងពួកស្តេច បានធ្លាក់ចូលក្នុងអន្ទាក់មរណៈរបស់ពួកខ្មែរក្រហម ប្រហែលគ្នានឹងគេខ្ទប់ ដោយខៀវសំផនគ្មានបានធ្វើអ្វីទាំងអស់ គ្រាន់តែបញ្ឆោឲ្យក្រុមខ្មែរក្រហមនៅជុំវិញទ្រង់រណ

ឫទ្ធិ ដកថយទៅសំរាកនៅអូរស្មាច់តែប៉ុណ្ណោះ ។

★★★ បើយើងបកត្រឡប់ថយក្រោយវិញ ប៉ុល-ពតបានធ្វើការព្រមានដល់ពួកស្តេចជាមុនរួចទៅហើយ ប៉ុន្តែគ្មាននរណាជឿ ៖

«បានឆ្នាំងតូច កុំភ្លេចឆ្នាំងធំ
បានសារុងពុម្ព កុំភ្លេចសំពត់ខ្មៅ
ពេលយួនចេញទៅ មួយរណ្តៅ១០០នាក់» ។

★★★ ឃើញថា ព្រឹត្តិការណ៍តូចធំទាំងប៉ុន្មាន ដែលកើតមានឡើងនៅប្រទេសកម្ពុជា តាំងពីសម័យឆ្នាំ៧០រហូតមកទល់សព្វថ្ងៃ មិនបានរួចផុតពីអង្គការភ្នែកម្នាស់របស់ប៉ុល-ពតសោះឡើយ ។ នៅទីបំផុតពួកស្តេចដែលបានគេចរួចពីប៉ុល-ពត ក៏បានមកជួបប្រទះនឹងហ៊ុន-សែន ដែលជាប៉ុល-ពតម្នាក់ទៀត ហើយក៏រមៀលធ្លាក់ចូលរណ្តៅរាប់រយនាក់ពិតមែន (រណ្តៅដែលពួកស្តេចបានជីកបំរុងកប់ពួកខ្មែរក្រហម វាបែរទៅជាកប់រូបខ្លួនឯងទៅវិញ)... មិនត្រឹមតែប៉ុណ្ណោះ ត្រូវគេខ្វេះភ្នែកគ្រប់គ្នា ដោយព្រោះតែភ្នែកឥតប្រស្រី សម្លឹងឃើញហ៊ុន-សែនថាជាយួន តាមពិតហ៊ុនសែនជាខ្មែរក្រហមទៅវិញសោះ ។

★★★ វាមានច្រកផ្លូវដំណោះស្រាយតែពីរយ៉ាងប៉ុណ្ណោះ ៖ ប្រសិនបើហ៊ុន-សែនជាយួន... នោះគឺពួកស្តេចចាញ់បោកអាមេរិកាំង ពោលត្រូវអាមេរិកាំងបញ្ឆោតយកទៅឲ្យយួនសម្លាប់អស់រលីង ! (ម្តេចក៏ថាហ៊ុន-សែនមិនមែនយួន ?? ហ៊ុន-សែននោះហើយ គឺយួនបានដាក់តាំងបន្តុបនៅលើអំណាចដោយជាក់ស្តែង) ។ ប្រសិនបើហ៊ុន-សែនជាខ្មែរក្រហមវិញ គឺពួកខ្មែរក្រហមនោះហើយ ដែលបានបោកបញ្ឆោតពួកស្តេច និងពួកយួនដែលសហការគ្នា ដើម្បីសម្លាប់ខ្មែរក្រហម <u>ឲ្យសម្លាប់គ្នាទៅវិញទៅមក</u> (ហេតុម្តេចក៏ថាហ៊ុន-សែនមិនមែនខ្មែរក្រហម ?? នៅក្នុងរង្វង់ពួកយួន ហ៊ុន-សែនជារដ្ឋមន្ត្រីទី១ពិតមែន ប៉ុន្តែនៅក្នុងរង្វង់ពួកខ្មែរក្រហមវិញ ដោយជាក់ស្តែង ហ៊ុន-សែនគ្រាន់តែជាកូនឈ្លបមួយរបស់តាម៉ុកប៉ុណ្ណោះ... ចំណែកតាម៉ុកវិញ ដោយជាក់ស្តែងគ្រាន់តែជាកូនជីងរបស់ប៉ុល-ពត !) ។

★★★ តើតាម៉ុកបានសម្លាប់ប៉ុល-ពតមែនឬទេ ? ក្នុងប្រការនេះ តាម៉ុកបាននិយាយត្រង់ប្រាប់ Nates Thayer នៅក្នុងពិធីដុតខ្មោចប៉ុល-ពតថា ៖ «ប៉ុល-ពតនេះជាយួនទេ» (មានចុះនៅក្នុង Far Eastern Economic Review ថ្ងៃដែលប៉ុល-ពតស្លាប់)...ក៏ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងលោកនេះ ជឿតាម៉ុកទាល់តែសោះ ។ តាមពិតខ្មោចប៉ុល-ពតនោះ គឺជាខ្មោចយួនម្នាក់មានមុខមាត់ស្រដៀងប៉ុល-ពត ដែលតាម៉ុកបានយកទៅដុត ឲ្យទៅជាអ្នកតាឃ្លាំងមឿងទី២ គឺដើម្បីទៅគៀងគរទ័ពខ្មោចមកបណ្តាលចិត្តឲ្យពួកយួនឈ្លានពានសម្លាប់ខ្លួនដោយដៃខ្លួនឯងតែប៉ុណ្ណោះ ។

❑

# ករណីរបស់លោកសម-រង្ស៊ី

លោកសម-រង្ស៊ីជាអ្នកនយោបាយសល់តែម្នាក់គត់ នៅក្នុងក្រឡាអុករបស់អាមេរិកាំង ដើម្បីទប់ទល់ជាមួយពួកខ្មែរក្រហម ។ លោកសម-រង្ស៊ីជាអ្នកបានបង្កើតបក្ស«ជាតិខ្មែរ» ...ដូច្នេះតើលោកសម-រង្ស៊ីជាអ្នកស្នេហាជាតិមែនឬទេ ? ចំណុចនេះហាក់ដូចជាមិនសូវប្រាកដ ៖

ទី១- លោកសម-រង្ស៊ីបានទទួលប្រាក់៣លានដុល្លារពីអៀង-សារី ដើម្បីបង្កើត«បក្សជាតិខ្មែរ» ។ ដូច្នេះសម-រង្ស៊ីនេះបិតនៅក្នុងបនប៉ុល-ពត, អៀង-សារីទេតើ គឺបនប្រល័យពូជសាសន៍...

ទី២- នៅពេលដែលហ៊ុន-សែន បានណែនាំខៀវ-សំផនឲ្យចូលមកក្នុងសង្គមជាតិវិញ គឺសម-រង្ស៊ីនេះហើយ ដែលបានស្នើរឲ្យមានតុលាការកាត់ទោសខៀវ-សំផន... ដូច្នេះសម-រង្ស៊ីនេះបង្ហាញថាខ្លួនបិតនៅក្នុងបនពួកឃ្លួនឃ្លានពានទឹកដី ! តើឯណាទៅ សេចក្ដីស្មោះត្រង់របស់សម-រង្ស៊ីនោះ ?

ទី៣- នៅពេលដែលហ៊ុន-សែនស្វែងសុំជំនួយបរទេស ដើម្បីកសាងសេដ្ឋកិច្ចកម្ពុជា... សម-រង្ស៊ីបែរជាដើរសុំឲ្យប្រទេសខាងលិចនិងជប៉ុន កាត់ផ្ដាច់ជំនួយពីប្រទេសខ្មែរទៅវិញ ។ សម-រង្ស៊ីថែមទាំងបានសុំឲ្យសហរដ្ឋអាមេរិកកាត់ផ្ដាច់កូតានៃការដឹកនាំសំលៀកបំពាក់ពីប្រទេសកម្ពុជាថែមទៀត ! ត្រង់ណាទៅដែលបង្ហាញថា លោកសម-រង្ស៊ីបានបំរើផលប្រយោជន៍របស់កម្មករខ្មែរ ?

ទី៤- នៅពេលដែលហ៊ុន-សែនបង្ហាញថា ខ្លួនលែងជាកុម្មុយនិស្តទៅហើយ សម-រង្ស៊ីបែរជាយកលទ្ធិកុម្មុយនិស្តចូលក្នុងកម្ពុជាវិញ គឺដោយបានបង្កើតសហ-ជីព ។ សហជីពនេះជាអាវុធរបស់កុម្មុយនិស្ត ដើម្បីពិឃាតលទ្ធិសេរីទេតើ ! មិនត្រឹមតែប៉ុណ្ណោះ សម-រង្ស៊ីបានដឹកនាំបំបះបំបោរកម្មករ ឲ្យទៅឲ្យឃ្មួនគប់គ្រាប់បែកស្លាប់អស់ជាង១០០នាក់ ហើយចោទប្រកាន់ថា ហ៊ុន-សែនជាឃាតករ បណ្ដាលឲ្យផ្អើលមតិពិភពលោកអស់យូរអង្វែងឆ្នាំ...។ ស្រាប់តែក្នុងពេលបច្ចុប្បន្ន សម-រង្ស៊ីប្រែជាធ្វើសេចក្ដីថ្លែងការណ៍បញ្ច្រាស់ទិសទៅវិញ (ដូចសត្វក្រពើហែលបញ្ច្រាស់ទឹក ហើយក្លែងខ្លួនឯងជាដុំឈើអង្កត់អុស) គឺបានថ្លែងថា មិនមែនហ៊ុន-សែនទេដែលគប់គ្រាប់បែក ។ យើងមានចម្ងល់ថា បើហ៊ុន-សែនមិនមែនជាអ្នកគប់គ្រាប់បែកទេ វាមានតែសម-រង្ស៊ីជាឃាតករគប់គ្រាប់បែកខ្លួនឯង ??

ទី៥- នៅទីបំផុត សម-រង្ស៊ីអស់កេរ្តិ៍ឈ្មោះរលីងជាអ្នកនយោបាយ គឺនៅសល់តែសម្លេងច្រេកៗយ៉ាងគ្រលួចដូចសត្វចង្រិតដែកអញ្ចឹង (ពីព្រោះចង្រិតដែកស្រែកពុខ្លាំងណាស់) ម៉្លោះហើយត្រូវក្មេងឃ្វាលគោ (ហ៊ុន-សែន)ចាប់ប្រជល់ជាមួយចង្រិតដែកមួយទៀត (កឹម-សុខា) ឲ្យស្លាប់ខ្លួនទាំងពីរនាក់ ។ ពីថ្ងៃនេះតទៅ សហការអាមេរិកាំង-យួន ដើម្បីទប់ទល់ឥទ្ធិពលចិននៅប្រទេសកម្ពុជា គឺត្រូវដាច់ឫសត្រឹមនេះឯង ! ។៚